# ថ្នាំបង្ការ Td ឬ Tdap ( តេតានុស-ខាន់ស្លាក់ ឬតេតានុស-ខាន់ស្លាក់-ក្អកមាន់ ) ថ្នាំបង្ការ

## អ្វីដែលអ្នកត្រូវដឹង

Many Vaccine Information Statements are available in Spanish and other languages. See www.immunize.org/vis.

សារព័ត៌មានថ្នាំចាក់បង្ការមួយចំនួន មានសរសេរជាភាសាអេស្ប៉ាញ និងភាសាដទៃទៀត ។ សូមទស្សនា គេហទំព័រ www.immunize.org/vis ។

## 1 ហេតុអ្វីត្រូវចាក់ថ្នាំបង្ការ ?

**ជំងឺតេតានុស ខាន់ស្លាក់ និងជំងឺក្អកមាន់** អាចជាជំងឺដ៏ធ្ងន់ធ្ងរ មួយ ។

**តេតានុស** ( ជំងឺរឹងថ្គាម ) ធ្វើឲ្យឈឺការកន្ត្រាក់សាច់ដុំ និងធ្វើឲ្យសាច់ដុំឡើងរឹង ជាធម្មតាវាប៉ះពាល់ដល់សាច់ដុំ ពេញរាងកាយ ។

- វាធ្វើឲ្យសាច់ដុំថ្ពៃមុខ និងកឡើងតឹង ដូច្នេះហើយបានជាអ្នកជំងឺមិនអាចហាមាត់ រួច ឬមិនអាចលេបអ្វីចូលបាន ជួនកាល អ្នកជំងឺមិនអាចដកដង្ហើមបានទៀតផង ។ ជំងឺតេតានុស សម្លាប់មនុស្សប្រហែលជា 1 នាក់ ក្នុងចំណោម 5 នាក់ដែលកើត ជំងឺនេះ ។

**ជំងឺខាន់ស្លាក់** អាចបណ្តាលឲ្យភ្នាសក្រាស់ឡើងប៉ោង ក្នុងបំពង់កផ្នែកខាងក្រោយ ។

- វាអាចនាំឲ្យពិបាកដកដង្ហើម អ្នកជំងឺខ្វាទចលនាស្លុកស្ពឹង បេះដូងឈប់ធ្វើចលនា ហើយក៏អាចបណ្តាលឲ្យស្លាប់ទៀតផង ។

**ក្អកខ្លាំង។** ( ជំងឺក្អកមាន់ ) បណ្តាលឲ្យអ្នកជំងឺក្អកខ្លាំង ដែល អាចធ្វើឲ្យពិបាកដកដង្ហើម ធ្វើឲ្យក្អួត និងរំខានដំណេក ។

- វាអាចបណ្តាលឲ្យអកជំងឺស្រកទំងន់ នេវនាវ ស្រាំឆ្អឹងជំនី ហើយអាចឲ្យអ្នកជំងឺ សន្លប់ទៀតផង ។ មានចំនួនអ្នកកើតជំងឺនេះរហូតដល់ទៅ 2 នាក់ ក្នុងចំណោមយុវវ័យ 100 នាក់ និង 5 នាក់ ក្នុង ចំណោមមនុស្សចាស់ 100 នាក់ ដែលកើតជំងឺក្អកមាន់ ត្រូវសំរាកពេទ្យ ឬកើតជំងឺផ្សេងៗទៀតមកជាមួយ ដោយរួមទាំង ជំងឺរលាកទងសួត និងស្លាប់បាត់បង់ជីវិត ។

ជំងឺទាំងបីប្រភេទនេះ បណ្តាលមកពីមេរោគបាក់តេរី ។ ជំងឺខាន់ស្លាក់ និងជំងឺក្អកមាន់ អាចឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ បាន ។ ជំងឺតេតានុសឆ្លងចូលក្នុងរាងកាយ មនុស្សតាមស្នាមមុត ដាច់ស្បែក ឬរបួស ។

នៅសហរដ្ឋអាមេរិក មានមនុស្សចំនួន 200,000 នាក់ ក្នុងមួយឆ្នាំ កើតជំងឺខាន់ស្លាក់ និងជំងឺក្អកមាន់ ហើយមានករណីរាប់រយ បានកើតជំងឺតេតានុស នៅមុនពេលមានថ្នាំចាក់បង្ការ ។ ចាប់ តាំងពីមានថ្នាំចាក់បង្ការមក ករណីកើតជំងឺតេតានុស និងជំងឺខាន់ស្លាក់ មានការធ្លាក់ចុះ ប្រហែលជា 99% ហើយជំងឺក្អកមាន់ បានធ្លាក់ចុះប្រហែលជា 92% ។

កុមារដែលមានអាយុ 6 ឆ្នាំ និងក្មេងជាងនេះ ត្រូវទទួលថ្នាំបង្ការ DTaP ដើម្បីការ ពារពួកគេកុំឲ្យកើតជំងឺទាំងបីប្រភេទនេះ ។ តែ កុមារដែលមានអាយុច្រើនជាងនេះ យុវវ័យ និងមនុស្សចាស់ ក៏ត្រូវការការពារផងដែរ ។

## 2 ថ្នាំបង្ការ សម្រាប់យុវវ័យ និងមនុស្សចាស់ ៖ Td និង Tdap

មានថ្នាំបង្ការចំនួនពីរ សម្រាប់ការពារកុមារដែលមានអាយុ 7 ឆ្នាំ និងចាស់ជាងនេះ ពីជំងឺទាំងនេះ ៖

- **ថ្នាំបង្ការ Td vaccine** ត្រូវបានយកមកប្រើប្រាស់អស់រយៈពេល ជាច្រើនឆ្នាំ ។ វាជាថ្នាំបង្ការជំងឺតេតានុស និងជំងឺខាន់ស្លាក់ ។
- **ថ្នាំបង្ការ Tdap** ត្រូវបានចេញលិខិតឲ្យប្រើប្រាស់ក្នុងឆ្នាំ 2005 ។ វាជាថ្នាំបង្ការ ដំបូងសម្រាប់យុវវ័យ និងមនុស្សចាស់ ដែលជួយការពារជំងឺក្អកមាន់ តេតានុស និងជំងឺខាន់ស្លាក់ ។

ថ្នាំបង្ការ Td សម្រាប់ចាក់រំឭក គឺបានណែនាំឲ្យចាក់ក្នុងរវាង 10 ឆ្នាំម្តង ។ រីឯថ្នាំបង្ការ Tdap វិញ ត្រូវចាក់តែម្តងទេ ក្នុងមួយ ជីវិត ។

## 3 តើអ្នកត្រូវចាក់ថ្នាំបង្ការមួយណា និងចាក់នៅ ពេលណា?

***ចាប់ពីអាយុ 7 ឆ្នាំ ដល់ 18 ឆ្នាំ***

- ការចាក់ថ្នាំបង្ការ Tdap ឲ្យគ្រប់ដូស គឺត្រូវចាក់ក្នុងពេលអ្នកមានអាយុ 11 ឬ 12 ឆ្នាំ ។ ដូសនេះ អាចចាក់បានដែរពេលកុមារ មានអាយុ 7 ឆ្នាំ សម្រាប់កុមារដែលមិនបានចាក់ DTaP មួយដូស ឬច្រើនដូសពេលគេនៅតូច ។
- កុមារ និងយុវវ័យ ដែលមិនបានចាក់ DTaP គ្រប់ចំនួន ពេលដែលគេមានអាយុគ្រប់ 7 ឆ្នាំ គួរតែចាក់ឲ្យគ្រប់ចំនួន ដោយការចាក់រួមគ្នានៃ Td និង Tdap ។

***អាយុ 19 ឆ្នាំ និងចាស់ជាងនេះ***

- មនុស្សចាស់ទាំងអស់ គួរចាក់ថ្នាំបង្ការ Td ជាលក្ខណៈរំឭក ក្នុងរវាង 10 ឆ្នាំ ម្តង ។ មនុស្សចាស់ដែលមានអាយុក្រោម 65 ឆ្នាំ ដែលមិនធ្លាប់បានទទួលថ្នាំបង្ការ Tdap គួរចាក់ថ្នាំ Tdap នេះ មួយដូស សម្រាប់ជាដូសចាក់រំឭកមួយ ។ មនុស្សចាស់ ដែលមានអាយុ 65 ឆ្នាំ ឬចាស់ជាងនេះ អាច ចាក់ Tdap មួយដូសជាការរំឭក ។
- មនុស្សចាស់ (រួមទាំងស្ត្រី ដែលអាចមានផ្ទៃពោះ ព្រមទាំងមនុស្សដែលមានអាយុ 65 ឆ្នាំ ឬចាស់ជាងនេះ ) ដែលរំពឹងថាត្រូវនៅក្បែរទារកដែលមានអាយុក្រោម 12 ខែ គួរតែចាក់ថ្នាំបង្ការ Tdap មួយដូស ដើម្បីជួយការពារទារកពីជំងឺក្អកមាន់ ។
- អ្នកឯកទេសថែទាំសុខភាព ដែលប៉ះពាល់អ្នកជំងឺដោយផ្ទាល់ នៅមន្ទីរពេទ្យ ឬគ្លីនិក គួរចាក់ថ្នាំបង្ការ Tdap មួយដូស ។

***ការការពារក្រោយពេលមានរបួស***

- អ្នកដែលមុត ឬរលាកធ្ងន់ធ្ងរ អាចត្រូវចាក់ថ្នាំបង្ការ Td ឬ Tdap មួយដូស ដើម្បី ការពារការឆ្លងមេរោគតេតានុស ។ ថ្នាំបង្ការ Tdap គួរប្រើជាមួយនឹងនរណា ដែល មិនធ្លាប់បានទទួលដូសនេះពីមុនមក ។ យើងគួរតែយកថ្នាំបង្ការ Td មកប្រើ ប្រសិនបើយើងមិនមានថ្នាំបង្ការ Tdap ទេនោះ ឬគួរយកមកប្រើជាមួយ ៖
  - នរណាម្នាក់ ដែលបានទទួលដូស Tdap រួចមកហើយ
  - កុមារដែលមានអាយុពី 7 ដល់ 9 ឆ្នាំ ដែលបានទទួលថ្នាំបង្ការ DTaP គ្រប់ចំនួនដូសកាលពីនៅតូច ឬប្រើជាមួយ
  - មនុស្សចាស់ដែលមានអាយុចាប់ពី 65 ឆ្នាំឡើងទៅ ។

***ស្ត្រីមានផ្ទៃពោះ***

- ស្ត្រីមានផ្ទៃពោះ ដែលមិនធ្លាប់បានទទួលដូសនៃថ្នាំបង្ការ Tdap គួរតែចាក់មួយដូស ក្រោយពីពពោះបានចំនួន 20សប្តាហ៍ និងជាការល្អគួរចាក់ក្នុងពេលពពោះបាន បីខែ ។ បើស្ត្រីមានគភ៌ មិនបានទទួលថ្នាំបង្ការ Tdap ក្នុងពេលពពោះទេនោះ នាងគួរតែបានទទួលមួយដូស ភ្លាមៗក្រោយពេលសម្រាល ។ ស្ត្រីមានគភ៌ ដែល បានទទួលថ្នាំបង្ការ Tdap កាលពីពេលមុនរួចហើយ ហើយត្រូវការចាក់ថ្នាំបង្ការ តេតានុស ឬថ្នាំបង្ការជំងឺខាន់ស្លាក់ ក្នុងពេលពពោះ គួរតែចាក់ Td ។

ថ្នាំបង្ការ Tdap ឬ Td អាចចាក់បានក្នុងពេលតែមួយ ដូចថ្នាំបង្ការ ដទៃទៀតដែរ ។

## 4 អ្នកខ្លះមិនគួរចាក់ថ្នាំបង្ការនេះទេ ឬគួររង់ចាំសិន

- អ្នកដែលមានការប្រឈមនឹងគ្រោះថ្នាក់ដល់ជីវិត ពីការប្រតិកម្មថ្នាំ ក្រោយការចាក់ថ្នាំ បង្ការមួយដូស នៃថ្នាំបង្ការ ជំងឺតេតានុស ខាន់ស្លាក់ ឬក្អកមាន់ មិនគួរចាក់ថ្នាំបង្ការ Td ឬ Tdap ឡើយ ។
- អ្នកណាម្នាក់ដែលមានប្រតិកម្មខ្លាំងក្លា ចំពោះសមាសធាតុថ្នាំបង្ការណាមួយ មិនគួរចាក់ ថ្នាំបង្ការនេះឡើយ ។ សូមប្រាប់ គ្រូពេទ្យរបស់អ្នកឲ្យបានដឹង ប្រសិនបើអ្នកដែលមក ចាក់ថ្នាំ បង្ការ មានប្រតិកម្មថ្នាំធ្ងន់ធ្ងរ ។
- នរណាម្នាក់ដែលកើតជំងឺរលត់ស្មារតី ឬកើតជំងឺក្នុងរយៈពេលវែង ឬកើតជំងឺច្រើនមុខ ក្នុងរវាង 7 ថ្ងៃ ក្រោយពេលបានទទួលថ្នាំ DTP ឬ DTaP មួយដូស មិនគួរចាក់ Tdap ឡើយ ប្រសិនបើ មិនមានការរកឃើញថា មូលហេតុនៃការកើតជំងឺ ដោយសាររឿងផ្សេង ក្រៅពីថ្នាំបង្ការទេនោះ ។ អ្នកទាំងនេះ ប្រហែលជាអាចទទួលថ្នាំបង្ការជំងឺ Td បាន ។

U.S. Department of Health and Human Services
Centers for Disease Control and Prevention

- ចូរប្រាប់ឲ្យគ្រូពេទ្យបានដឹង ប្រសិនបើអ្នកមកចាក់ថ្នាំបង្ការ កើតជំងឺណាមួយដូចជា ៖
  - ជំងឺឃ្លង់ ឬបានបញ្ហាជំងឺប្រព័ន្ធសរសៃប្រសាទផ្សេងទៀត
  - ហើម ឬឈឺខ្លាំង ក្រោយពេលចាក់មួយដូសមុន នៃថ្នាំបង្ការ DTP, DTaP, DT, Td ឬថ្នាំបង្ការ Tdap ឬ
  - កើត Guillain Barré Syndrome (GBS-ជំងឺពិការប្រព័ន្ធ សរសៃប្រសាទ) ។

នរណាម្នាក់ដែលឈឺមធ្យម ឬធ្ងន់ធ្ងរ ក្នុងថ្ងៃមកចាក់ថ្នាំបង្ការនេះ គួររង់ចាំរហូតដល់ជាសះស្បើយ មុននឹងចាក់ថ្នាំបង្ការ Tdap ឬ Td ។ អ្នកណាដែលឈឺតិចតួច ឬក្តៅខ្លួនតិចៗ អាចចាក់ ថ្នាំបង្ការនេះបាន ។

## 5 តើមានហានិភ័យអ្វីទេចំពោះថ្នាំបង្ការ Tdap និង Td?

ថ្នាំបង្ការ ក៏ដូចជាថ្នាំទូទៅ តែងតែមានហានិភ័យតិចតួច ចំពោះប្រតិកម្មបញ្ច្រាសទិស ចំពោះគ្រោះថ្នាក់ដល់ជីវិត ឬបញ្ហាធ្ងន់ធ្ងរផ្សេងទៀត ។

បាត់ស្មារតីបន្តិច និងមានរោគសញ្ញាដែលពាក់ព័ន្ធ (ដូចជាមានចលនាញាក់ៗ) អាចកើតឡើង ក្រោយពេលធ្វើទម្រង់ការវេជ្ជសាស្ត្រណាមួយ មានរួមទាំងចាក់ថ្នាំបង្ការ ។ ចូរអង្គុយ ឬដេកចំនួនប្រហែលជា 15 នាទី ក្រោយពេលចាក់ថ្នាំបង្ការ អាចជួយការពារការវិលមុខ និងរបួសស្នាម បណ្តាលពីការដួល ។ ចូរប្រាប់ឲ្យគ្រូពេទ្យបានដឹង ប្រសិនបើអ្នកចាក់វ៉ាក់សាំងរួច មានអារម្មណ៍វិលមុខ ឬឈឺក្បាលតិចៗ ឬមើលឃើញអ្វីខុស ប្រកតី ឬហ៊ឹងត្រចៀក ។

ការកើតជំងឺតេតានុស ខាន់ស្លាក់ ឬជំងឺក្អកមាន់ អាចបង្កឲ្យមានបញ្ហាធ្ងន់ធ្ងរខ្លាំងជាងបញ្ហាពីថ្នាំបង្ការ Td ឬ Tdap ។

បញ្ហានានាដែលគេបានរាយការណ៍ឲ្យបានដឹង ក្រោយទទួលថ្នាំបង្ការ Td និង Tdap មានដូចខាងក្រោម ។

**បញ្ហាតិចតួច**
*(អាចកត់សំគាល់ឃើញបាន តែមិនបង្ករការរំខានដល់សកម្មភាព ឡើយ)*

***Tdap***
- ឈឺ (ប្រហែលជា 3 នាក់ក្នុងចំណោម 4 នាក់យុវវ័យ និង 2 នាក់ក្នុងចំណោម 3 នាក់មនុស្សចាស់)
- ឡើងក្រហម ឬហើមត្រង់បរិវេណចាក់ម្ជុល (ប្រហែល 1 ក្នុង 5 នាក់)
- គ្រុនក្តៅតិចតួច ដែលខ្លួនឡើងកំដៅយ៉ាងហោចណាស់ក៏ 100.4°F (រហូតដល់ទៅ 1 នាក់ ក្នុងចំណោម 25 នាក់យុវវ័យ និង 1 នាក់ក្នុង 100 នាក់មនុស្សចាស់)
- ឈឺក្បាល (ប្រហែល 4 នាក់ ក្នុងចំណោម 10 នាក់យុវវ័យ និង 3 នាក់ក្នុងចំណោម 10 នាក់មនុស្សចាស់)
- ហេវហត់ (ប្រហែលជា 1 នាក់ក្នុងចំណោម 3 នាក់យុវវ័យ និង 1 នាក់ក្នុងចំណោម 4 នាក់មនុស្សចាស់)
- ចង់ក្អួត ក្អួត រាគ ឈឺពោះ (រហូតដល់ទៅ 1 នាក់ក្នុងចំណោម 4 នាក់យុវវ័យ និង 1 នាក់ក្នុងចំណោម 10 នាក់មនុស្សពេញវ័យ)
- រងារញ័រញាក់ ឈឺខ្លួន ឈឺសន្លាក់ ឡើងកន្ទួល ហើមកូនកណ្តុរ (មិនធម្មតា)

***Td***
- ឈឺ (រហូតដល់ទៅ ៨ ក្នុងចំណោម 10នាក់)
- ឡើងក្រហម ឬហើមត្រង់បរិវេណចាក់ម្ជុល (រហូតដល់ទៅ 1 នាក់ក្នុងចំណោម 3 នាក់)
- គ្រុនក្តៅតិចតួច (រហូតដល់ទៅមួយ 1 នាក់ ក្នុងចំណោម 15នាក់)
- ឈឺក្បាល ឬអស់កម្លាំង (មិនប្រកតី)

**មញ្ហាមធ្យម**
*(ធ្វើឲ្យរំខានដល់សកម្មភាពនានា តែមិនចាំបាច់ព្យាបាលឡើយ)*

***Tdap***
- ឈឺត្រង់បរិវេណចាក់ម្ជុល (ប្រហែល 1 នាក់ ក្នុងចំណោម 20 នាក់យុវវ័យ និង 1 នាក់ ក្នុងចំណោម 100 នាក់មនុស្សចាស់)
- ឡើងក្រហម ឬហើមត្រង់បរិវេណចាក់ម្ជុល (រហូតដល់ទៅ 1 នាក់ ក្នុងចំណោម 16 នាក់យុវវ័យ និង 1នាក់ ក្នុងចំណោម 25 នាក់មនុស្សចាស់)
- គ្រុនឡើងកំដៅលើសពី 102°F (ប្រហែល 1 នាក់ ក្នុងចំណោម 100 នាក់ យុវវ័យ និង 1 នាក់ ក្នុងចំណោម 250 នាក់មនុស្សចាស់)
- ឈឺក្បាល (1 នាក់ ក្នុងចំណោម 300 នាក់)
- ចង់ក្អួត ក្អួត រាគ ឈឺពោះ (រហូតដល់ទៅ 3 នាក់ ក្នុងចំណោម 100 នាក់យុវវ័យ និង 1 នាក់ ក្នុងចំណោម 100 នាក់មនុស្សចាស់)

***Td***
- គ្រុនឡើងកំដៅលើសពី 102°F (កម្រ)

***Tdap ឬ Td***
- ហើមដៃខ្លាំង ត្រង់បរិវេណចាក់ម្ជុល (រហូតដល់ទៅ 3 នាក់ ក្នុងចំណោម 100 នាក់) ។

**បញ្ហាធ្ងន់ធ្ងរ**
*(មិនអាចធ្វើសកម្មភាពធម្មតាបាន ត្រូវឲ្យពេទ្យព្យាបាល)*

***Tdap ឬ Td***
- ហើម ឈឺខ្លាំង ចេញឈាម និងឡើងក្រហម លើដៃ ត្រង់បរិវេណចាក់ម្ជុល (កម្រ) ។

ប្រតិកម្មបញ្ច្រាសទិសធ្ងន់ធ្ងរ អាចកើតឡើង ក្រោយពេល ទទួលថ្នាំបង្ការណាមួយ ។ តែចំនួនប៉ាន់ស្មានដែលករណីនេះ អាចកើតឡើងមានចំនួនតិចជាងមួយដង ក្នុងមួយលានដូស ។

## 6 តើត្រូវធ្វើដូចម្តេច បើមានប្រតិកម្មធ្ងន់ធ្ងរកើតឡើង?

**តើខ្ញុំគួររកមើលអ្វី?**
ចំពោះស្ថានភាពមិនប្រកតី មានដូចជាប្រតិកម្មបញ្ច្រាសទិសធ្ងន់ធ្ងរ ឬគ្រុនក្តៅខ្លាំង ។ ប្រសិនបើមានប្រតិកម្មបញ្ច្រាស ទិសធ្ងន់ធ្ងរកើតឡើង វានឹងកើតឡើងក្នុងរវាងពីរបីនាទីទៅមួយ ម៉ោង បន្ទាប់ពីចាក់រួច ។ សញ្ញានៃប្រតិកម្មបញ្ច្រាសទិសធ្ងន់ធ្ងរ មានដូចជា ពិបាកដកដង្ហើម ខ្សោយកម្លាំង ដកដង្ហើមឮងឺតៗ ឬរ៉ឺតៗ បេះដូងដើរញាប់ ឡើងបន្ទាលត្រអាក វិលមុខ ស្លេក ឬ ហើមបំពង់ក ។

**តើខ្ញុំគួរធ្វើអ្វី?**
- ហៅទូរស័ព្ទមកជួបគ្រូពេទ្យ ឬបញ្ជូនអ្នកជំងឺមកជួបគ្រូពេទ្យជាបន្ទាន់ ។
- ប្រាប់គ្រូពេទ្យរបស់អ្នកពីអ្វីដែលបានកើតឡើង កាលបរិច្ឆេទ និងពេលវេលាដែលបានកើតឡើង និងពេលដែលអ្នកជំងឺបានទទួលការចាក់ថ្នាំបង្ការ ។
- ប្រាប់ដល់អ្នកផ្តល់សេវាឲ្យអ្នក ធ្វើរបាយការណ៍ពីប្រតិកម្ម បញ្ច្រាសទិសដោយការបំពេញសំណុំបែបបទ Vaccine Adverse Event Reporting System (VAERS-ប្រព័ន្ធការធ្វើ របាយការណ៍ហេតុការណ៍ប្រតិកម្មបញ្ច្រាស់ទិសរបស់ថ្នាំ បង្ការ) ។ ឬអ្នកក៏អាចរាយការណ៍អំពីរឿងនេះ តាមរយៈ គេហទំព័ររបស់ VAERS តាមរយៈអាសយដ្ឋាន **www.vaers.hhs.gov** ឬដោយការហៅទូរស័ព្ទមកកាន់លេខ **1-800-822-7967** ។

*VAERS មិនផ្តល់ជូនព័ត៌មានវេជ្ជសាស្ត្រឡើយ ។*

## 7 កម្មវិធីផ្តល់សំណងរបួសស្នាមបណ្តាលពីថ្នាំបង្ការ

The National Vaccine Injury Compensation Program (VICP-កម្មវិធីជាតិផ្តល់សំណងរបួសស្នាមបណ្តាលពីថ្នាំបង្ការ) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ 1986 ។

អ្នកដែលជឿជាក់ថាខ្លួនអាចមានរបួសស្នាមបណ្តាលពីថ្នាំបង្ការ អាចអានឲ្យបានដឹងពីកម្មវិធីផ្តល់សំណង និងរបៀបដាក់ពាក្យ ទារសំណង ដោយការហៅទូរស័ព្ទមកកាន់លេខ **1-800-338-2382** ឬទស្សនាគេហទំព័ររបស់ VICP ដែលមានអាសយដ្ឋាន **www.hrsa.gov/vaccinecompensation** ។

## 8 តើខ្ញុំអាចបានដឹងព័ត៌មានបន្ថែមដោយរបៀប ណា?

- គ្រូពេទ្យរបស់អ្នក អាចផ្តល់ឲ្យអ្នកនូវកញ្ចប់ព័ត៌មានថ្នាំ បង្ការ ដល់អ្នក ឬប្រាប់អ្នកពីប្រភពព័ត៌មានផ្សេងទៀតដល់អ្នក ។
- ចូរហៅទូរស័ព្ទទៅកាន់នាយកដ្ឋានសុខាភិបាលប្រចាំតំបន់ ឬនាយកដ្ឋានសុខាភិបាលប្រចាំរដ្ឋរបស់អ្នក ។
- ចូរទាក់ទងជាមួយនឹង Centers for Disease Control and Prevention (CDC-មជ្ឈមណ្ឌលគ្រប់គ្រង និងការពារជំងឺ) ៖
  - ហៅមកលេខ **1-800-232-4636 (1-800-CDC-INFO)** ឬ
  - ទស្សនាគេហទំព័ររបស់ CDC តាមរយៈអាសយដ្ឋាន **www.cdc.gov/vaccines**

---

Vaccine Information Statement (Interim)
Td & Tdap Vaccines
Cambodian
1/24/2012
42 U.S.C. § 300aa-26
Translation provided by the California Department of Public Health